ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

តុលាការរដ្ឋប្បវេណី

**សំណុំរឿងរដ្ឋប្បវេណីលេខ ៦០៣**

ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១

**សាលក្រមរដ្ឋប្បវេណីលេខ ០០៤ ប**

ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្ដាល

កាលបរិច្ឆេទនៃការបញ្ចប់ទាញហេតុផលដោយផ្ទាល់មាត់ ៖ ថ្ងៃទី២១ ខែមករា ឆ្នាំ២០២២។

កាលបរិច្ឆេទនៃការប្រកាសសាលក្រម ៖ ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២។

### ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល និងជាចៅក្រមជំនុំជម្រះ

### ក្រឡាបញ្ជី

លោកស្រី [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

**ក. អំពីអត្តសញ្ញាណភាគី**

**ដើមចោទ**

ឈ្មោះ [redacted] **វន** ភេទប្រុស កើតឆ្នាំ១៩៧៣ ជនជាតិខ្មែរ សញ្ជាតិខ្មែរ។

ទីលំនៅ[redacted]។

**អ្នកតំណាងដោយអាណត្តិ៖**

លោក [redacted] អត្តលេខ ២៣១៤T ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យ៖ [redacted]។

លោក [redacted] អត្តលេខ ២៣២១T ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យ៖ [redacted]។

**ចុងចម្លើយ**

ឈ្មោះ [redacted] **ហេង** ភេទស្រី អាយុ ៨០ ឆ្នាំ ជនជាតិខ្មែរ។

ទីលំនៅ[redacted]។

លោកស្រី [redacted] អត្តលេខ ២២២៧T ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យនៅ[redacted]។



Scanned with CamScanner

## អង្គហេតុ និងចំណុចវិវាទ

### ក. ខ្លឹមសារនៃពាក្យបណ្តឹងដែលដើមចោទទាមទារឱ្យតុលាការចេញ

១. បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted]ហេង ភេទស្រី អាយុ ៨០ ឆ្នាំ រុះរើផ្ទះសំភារៈផ្សេងៗចេញពីដី ធ្វើការបណ្តេញចេញ និងប្រគល់ដីចំនួន ០១ (មួយ) កន្លែងដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨១០០៩០១-០០៦៧ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១២ ក្បាលដីលេខ ៦៧ ទំហំផ្ទៃដីសរុប ១២៦៧ ម៉ែត្រការ៉េ (មួយពាន់ពីររយហុកសិបប្រាំពីរ) មានទីតាំងនៅភូមិកោះគរ សង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្តាល ដែលមានព្រំប្រទល់ខាង ជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងផ្លូវជាតិលេខ ២១ អា ខាងកើតទល់នឹង ដីលេខ ៦៦ ខាងលិចទល់នឹងដីលេខ ៦៨ មកឱ្យដើមចោទជាម្ចាស់កម្មសិទ្ធិករស្របច្បាប់វិញ នៅពេលសាលក្រមចូលជាស្ថាពរ។

២. បង្គាប់ឱ្យចុងចម្លើយទទួលខុសត្រូវលើប្រាក់ពន្ធ, ប្រាក់ក្រៅពីពន្ធ និងប្រាក់ប្រដាប់ក្តី។

### ខ. ដំណើររឿងក្តី និងចំណុចវិវាទ

#### ខ.១. ការសង្ខេបអំពីរឿងក្តី

ឈ្មោះ [redacted] ចាន់ គឺជាម្ចាស់ដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨១០០៩០១-០០៦៧ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១២ ក្បាលដីលេខ ៦៧ ទំហំផ្ទៃដីសរុប ១២៦៧ ម៉ែត្រការ៉េ (មួយពាន់ពីររយហុកសិបប្រាំពីរ) ទីតាំងនៅភូមិកោះគរ សង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្តាល ដែលមានព្រំប្រទល់ខាង ជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងផ្លូវជាតិលេខ ២១ អា ខាងកើតទល់នឹង ដីលេខ ៦៦ ខាងលិចទល់នឹងដីលេខ ៦៨ ដោយបានលក់ដីនេះឱ្យដើមចោទនៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០។ នៅពេលនោះឈ្មោះ [redacted] ចាន់ ក៏បានប្រាប់ចុងចម្លើយដែលជាបងបង្កើតរបស់ខ្លួនឈ្មោះ [redacted] ហេង ឱ្យចាកចេញពីដី ហើយចុងចម្លើយក៏បានយល់ព្រមដោយចុងចម្លើយបានអះអាងចំពោះមុខដើមចោទថា មិនអីទេ ព្រោះជាដីរបស់ឈ្មោះ [redacted]ចាន់។ ក្រោយមក ចុងចម្លើយមិនព្រមចាកចេញពីដីនេះ ដោយបែរជាយកលេសថា ជាដីកេរ្តិ៍ឪពុកម្តាយទៅវិញ។

#### ខ.២. អង្គហេតុដែលគ្មានវិវាទ៖ គ្មាន។

#### ខ.៣. អំពីចំណុចវិវាទ

**ខ.៣.១. ស្តីពីចំណុចវិវាទទី១៖**

តើការទាមទារដោយផ្អែកលើសិទ្ធិកម្មសិទ្ធិរបស់ដើមចោទត្រឹមត្រូវឬទេ?

**ខ.៣.២. ស្តីពីចំណុចវិវាទទី២៖**

តើការទាមទារឱ្យរុះរើសំភារៈផ្សេងៗ បណ្តេញចេញ ដោយផ្អែកលើសិទ្ធិកម្មសិទ្ធិត្រឹមត្រូវឬទេ?

#### ខ.៤. ការអះអាងរបស់ភាគីស្តីពីចំណុចវិវាទ

**ខ.៤.១. ស្តីពីចំណុចវិវាទទី១ និងទី២៖**

**ក. ការអះអាងរបស់ដើមចោទ៖**

១. ដើមចោទ៖ ខ្ញុំស្នើសុំដូចការទាមទារក្នុងពាក្យបណ្តឹង និងពាក្យបណ្តឹងបន្ថែមដោយស្នើសុំឱ្យចុងចម្លើយឈ្មោះ [redacted] ហេង រុះរើសំភារៈផ្សេងៗ ធ្វើការបណ្តេញចេញ ព្រមទាំងប្រគល់ដីចំនួន ០១ (មួយ) កន្លែង



Scanned with CamScanner

ដូចមានក្នុងកម្មវត្ថុនៃពាក្យបណ្តឹងខាងលើ ដោយខ្ញុំទិញពីប្អូនស្រីរបស់ចុងចម្លើយឈ្មោះ [redacted] ចាន់ នៅឆ្នាំ២០២០ ដោយមានកិច្ចសន្យាទិញលក់មានអាជ្ញាធរដឹងឮត្រឹមត្រូវ មានប្តង់រឹង (ឈ្មោះ [redacted] ចាន់) តែខ្លួនដឹងថា ឈ្មោះ [redacted] ហេង គ្រាន់តែមកស្នាក់នៅបណ្តោះអាសន្នមុនពេលខ្លួនទិញ ក្រោយពេលខ្លួនទិញស្រាប់តែឈ្មោះ [redacted] ហេង មិនព្រមចេញពីដីនេះតែម្តង ហេតុនេះខ្ញុំបាទស្នើសុំតុលាការសម្រេចតាមកម្មវត្ថុខាងលើ។

**២. អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ៖** ខ្ញុំនៅតែរក្សាខ្លឹមសារដូចមានក្នុងពាក្យបណ្តឹងចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០២១ និងពាក្យបណ្តឹងបន្ថែម ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ ទុកដដែល ដោយស្នើសុំឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយរុះរើផ្ទះសំភារៈផ្សេងៗចេញពីដី ធ្វើការបណ្តេញចេញ និងប្រគល់ដីចំនួន ០១ (មួយ) កន្លែង ឱ្យកូនក្តីខ្ញុំជាម្ចាស់កម្មសិទ្ធិស្របច្បាប់វិញនូវដីដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨១០ ០៩០១-០០៦៧ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១២ ដោយមូលហេតុដីនេះ កូនក្តីខ្ញុំបាទបានទិញពីម្ចាស់ដីឈ្មោះ [redacted] ចាន់ ដូចមានក្នុងកិច្ចសន្យាចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ និងមានចុះហត្ថលេខាដោយមេភូមិ និងចៅសង្កាត់ ដោយការទិញលក់នេះមានលក្ខណៈត្រឹមត្រូវស្របតាមផ្លូវច្បាប់ ហើយចំពោះចុងចម្លើយត្រូវជាបងបង្កើតរបស់ឈ្មោះ [redacted] ចាន់ គ្រាន់តែមកសុំប្អូនរស់នៅលើដីនេះជាបណ្តោះអាសន្នតែប៉ុណ្ណោះ។ កូនក្តីខ្ញុំបាទមានសាក្សីប្រជាពលរដ្ឋ មានភស្តុតាង និងមានអាជ្ញាធរបានដឹងឮផងដែរ ហើយកន្លងមកកូនក្តីខ្ញុំបាទក្នុងអំឡុងពេលទិញដីនេះក៏បានលឺដោយផ្ទាល់ផងដែរថា ឈ្មោះ [redacted] ហេង បានប្រាប់ទៅឈ្មោះ [redacted] ចាន់ ជាប្អូនថា ខ្លួនពុំទាន់បានចេញពីដីនេះដោយសារតែពុំទាន់រកកន្លែងថ្មីនៅបាន ពេលមានកន្លែងថ្មីខ្លួន ([redacted] ហេង) នឹងចាកចេញពីដីនេះភ្លាម រំលងបានប្រហែលប៉ុន្មានថ្ងៃ ស្រាប់តែឈ្មោះ [redacted] ហេង បានមកទាមទារប្រាក់ ពីប្អូនដែលជាម្ចាស់ដីឈ្មោះ [redacted] ចាន់ ចំនួន ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក បន្ថែមទៀត ទើបខ្លួនព្រមចេញ បើពុំនោះទេខ្លួន មិនចាកចេញពីដីនេះជាដាច់ខាត។

**ខ. ការអះអាងរបស់ចុងចម្លើយ៖** អវត្តមាន។

## សំអាងហេតុ

### ក. អំពីចំណុចវិវាទទី១

#### ក. ១. អំពីការទទួលស្គាល់អង្គហេតុ

តាមកិច្ចសន្យាលក់ផ្តាច់ដីផ្ទះចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ បង្ហាញថា ឈ្មោះ [redacted] ចាន់ បានលក់ដីលំនៅដ្ឋានដែលមានក្បាលដីលេខ ៦៧ ទំហំផ្ទៃដីសរុប ១២៦៧ ម៉ែត្រការ៉េ (មួយពាន់ពីររយហុកសិបប្រាំពីរ) មានទីតាំងនៅភូមិកោះគរ សង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្តាល ដែលមានព្រំប្រទល់ខាង ជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងផ្លូវជាតិលេខ ២១ អា ខាងកើតទល់នឹង ដីលេខ ៦៦ ខាងលិចទល់នឹងដីលេខ ៦៨ ឱ្យទៅដើមចោទ។ តាមវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨១០០៩០១-០០៦៧ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១២ បង្ហាញថា អចលនវត្ថុនេះមានក្បាលដីលេខ ៦៧ ទំហំផ្ទៃដីសរុប ១២៦៧ ម៉ែត្រការ៉េ (មួយពាន់ពីររយហុកសិបប្រាំពីរ) មានទីតាំងនៅភូមិកោះគរ សង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្តាល ដែលមានព្រំប្រទល់ខាង ជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងផ្លូវជាតិលេខ ២១ អា ខាងកើតទល់នឹង ដីលេខ ៦៦ ខាងលិចទល់នឹងដីលេខ ៦៨ និង



Scanned with CamScanner

មានកម្មសិទ្ធិករឈ្មោះ [redacted] ចាន់ និងតាមចម្លើយជាភស្តុតាងរបស់សាក្សីឈ្មោះ [redacted] ចាន់ ចម្លើយជាភស្តុតាងរបស់សាក្សីឈ្មោះ [redacted] សៀក និងចម្លើយជាភស្តុតាងរបស់សាក្សីឈ្មោះ [redacted] គឹមសេង តុលាការទទួលស្គាល់អង្គហេតុដែលដើមចោទបានទិញអចលនវត្ថុនេះពីឈ្មោះ [redacted] ចាន់ ដែលជាម្ចាស់កម្មសិទ្ធិ។

ហេតុនេះ ដើមចោទ គឺជាម្ចាស់កម្មសិទ្ធិករនៃអចលនវត្ថុដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ០៨១០០៩០១-០០៦៧ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១២ ក្បាលដីលេខ ៦៧ ទំហំផ្ទៃដីសរុប ១២៦៧ ម៉ែត្រការ៉េ (មួយពាន់ពីររយហុកសិបប្រាំពីរ) មានទីតាំងនៅភូមិកោះគរ សង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្តាល ដែលមានព្រំប្រទល់ខាង ជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងផ្លូវជាតិលេខ ២១ អា ខាងកើតទល់នឹង ដីលេខ ៦៦ ខាងលិចទល់នឹងដីលេខ ៦៨ តាមមាត្រា ១៣៣ នៃក្រមរដ្ឋប្បវេណី។

**ក.២. អំពីការវិនិច្ឆ័យ**

ដោយសារតែដើមចោទ គឺជាម្ចាស់កម្មសិទ្ធិនៃអចលនវត្ថុដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ០៨១០០៩០១-០០៦៧ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១២ ក្បាលដីលេខ ៦៧ ទំហំផ្ទៃដីសរុប ១២៦៧ ម៉ែត្រការ៉េ (មួយពាន់ពីររយហុកសិបប្រាំពីរ) មានទីតាំងនៅភូមិកោះគរ សង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្តាល ដែលមានព្រំប្រទល់ខាង ជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងផ្លូវជាតិលេខ ២១ អា ខាងកើតទល់នឹង ដីលេខ ៦៦ ខាងលិចទល់នឹងដីលេខ ៦៨ ហេតុនេះ ដើមចោទអាចធ្វើការទាមទារឱ្យប្រគល់មកវិញដោយផ្អែកលើកម្មសិទ្ធិ តាមមាត្រា ១៥៥ នៃក្រមរដ្ឋប្បវេណី។

**ខ. អំពីចំណុចវិវាទទី២**

**ខ.១. ការទទួលស្គាល់អង្គហេតុ**

តាមចម្លើយជាភស្តុតាងរបស់សាក្សីឈ្មោះ [redacted] ចាន់ ចម្លើយជាភស្តុតាងរបស់សាក្សីឈ្មោះ [redacted] សៀក និងចម្លើយជាភស្តុតាងរបស់សាក្សីឈ្មោះ [redacted] គឹមសេង បង្ហាញថា ចុងចម្លើយបានមកសុំដីរស់នៅឈ្មោះ [redacted] ចាន់ ដើម្បីស្នាក់នៅ និងឃើញថា ពុំមានឯកសារណាមួយដែលអាចបញ្ជាក់អំពីមូលហេតុគតិយុត្តិនៃសិទ្ធិកាន់កាប់តបជាមួយនឹងសិទ្ធិកម្មសិទ្ធិរបស់ដើមចោទ ឬរបស់អតីតកម្មសិទ្ធិឈ្មោះ [redacted] ចាន់ នោះទេ។ តុលាការទទួលស្គាល់ថា ដើមចោទអាចធ្វើការទាមទារឱ្យប្រគល់មកវិញដោយផ្អែកលើកម្មសិទ្ធិ តាមមាត្រា ១៥៥ នៃក្រមរដ្ឋប្បវេណី។

**ខ.២. ការវិនិច្ឆ័យ**

ដោយហេតុថា ចុងចម្លើយពុំមានមូលហេតុគតិយុត្តិនៃសិទ្ធិកាន់កាប់ចំពោះដើមចោទ ហេតុនេះ តុលាការនឹងសម្រេចបង្គាប់ឱ្យរុះរើផ្ទះសំភារៈផ្សេងៗចេញ និងប្រគល់ដីចំនួន ០១ (មួយ) កន្លែង ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨១០០៩០១-០០៦៧ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១២ ក្បាលដីលេខ ៦៧ ទំហំផ្ទៃដីសរុប ១២៦៧ ម៉ែត្រការ៉េ (មួយពាន់ពីររយហុកសិបប្រាំពីរ) មានទីតាំងនៅភូមិកោះគរ សង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្តាល ដែលមានព្រំប្រទល់ខាង ជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងផ្លូវជាតិលេខ ២១ អា ខាងកើតទល់នឹង ដីលេខ ៦៦ ខាងលិចទល់នឹងដីលេខ ៦៨ មកឱ្យដើមចោទ។



Scanned with CamScanner

**ឃគ. អំពីបន្ទុកនៃការប្រាក់ប្រដាប់ក្ដី**

**យល់ឃើញថា** តាមមាត្រា ៦៤ (ភាគដែលត្រូវទទួលបន្ទុក និងការសងវិញនូវប្រាក់ប្រដាប់ក្ដីដែលបានបង់រួចហើយ) មាត្រា ១៨២ កថាខណ្ឌទី៣ (ចំណុចដែលត្រូវវិនិច្ឆ័យដោយសាលក្រម) នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការនឹងសម្រេចលើបន្ទុកនៃប្រាក់ប្រដាប់ក្ដី នៅសាលាដំបូងឱ្យជាបន្ទុករបស់ចុងចម្លើយ។

**សេចក្ដីសម្រេចបញ្ចប់**

**១.** បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] **ហេង៖**

**ក.** រុះរើផ្ទះសំភារៈផ្សេងៗចេញពីដីចំនួន ០១ (មួយ) កន្លែង មានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨១០០៨០១-០០៦៧ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១២ ក្បាលដីលេខ ៦៧ ទំហំផ្ទៃដីសរុប ១២៦៧ ម៉ែត្រការ៉េ (មួយពាន់ពីររយហុកសិបប្រាំពីរ) ទីតាំងនៅភូមិកោះគរ សង្កាត់រការខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្ដាល ដែលមានព្រំប្រទល់ខាង ជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងផ្លូវជាតិលេខ ២១ អា ខាងកើតទល់នឹង ដីលេខ ៦៦ ខាងលិចទល់នឹងដីលេខ ៦៨។

**ខ.** ប្រគល់ដីចំនួន ០១ (មួយ) កន្លែង មានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨១០០៨០១-០០៦៧ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១២ ក្បាលដីលេខ ៦៧ ទំហំផ្ទៃដីសរុប ១២៦៧ ម៉ែត្រការ៉េ (មួយពាន់ពីររយហុកសិបប្រាំពីរ) ទីតាំងនៅភូមិកោះគរ សង្កាត់រការខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្ដាល ដែលមានព្រំប្រទល់ខាង ជើងទល់នឹងផ្លូវលំ ខាងត្បូងទល់នឹងផ្លូវជាតិលេខ ២១ អា ខាងកើតទល់នឹង ដីលេខ ៦៦ ខាងលិចទល់នឹងដីលេខ ៦៨ មកឱ្យដើមចោទ។

**២.** ប្រាក់ប្រដាប់ក្ដីនៅជាន់សាលាដំបូង គឺជាបន្ទុករបស់ចុងចម្លើយ។

ថ្ងៃ សុក្រ ១១ រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ខេត្តកណ្ដាល, ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ សុក្រ ១១ រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ខេត្តកណ្ដាល, ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២

**បានឃើញ**

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner